# ការឃុំខ្លួនរយៈពេល៨ឆ្នាំរបស់ ឌុច បានធ្វើឡើងមិនត្រឹមត្រូវតាមផ្លូវច្បាប់ឡើយ (ប៉ុន្តែអ្នកជាប់ឃុំនៅមន្ទីរស-២១ត្រូវបានទទួលរងអំពើ«ដូចមនុស្សគ្មានជីវិត» និង«ចាត់ទុកដូចជាសត្វធាតុ»)

*ដោយ ឡូវ៉ា ម៉ាក់ដូណល់*

*ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

## *សំណើសុំដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំត្រូវបានបដិសេធ ប៉ុន្តែការឃុំខ្លួនរបស់ ឌុច ដោយតុលាយោធាកម្ពុជាបានរំលោភសិទ្ធិរបស់ ឌុច*

ក្នុងសេចក្តីសម្រេចដែលរង់ចាំអស់រយៈពេលយ៉ាងយូរមកហើយ ថ្ងៃនេះអង្គជំនុំជម្រះបានប្រកាសថា ការឃុំខ្លួនជនជាប់ចោទ កាំង ហ្កេចអ៊ាវ (ឌុច) ដែលចេញសេចក្តីសម្រេចដោយតុលាការយោធា កម្ពុជារយៈពេលអស់ជាង៨ឆ្នាំ គឺមិនត្រឹមត្រូវតាមផ្លូវច្បាប់ និងរំលោភលើសិទ្ធិរបស់ជនជាប់ចោទ ។ ការឃុំខ្លួននេះ បានរំលោភដល់ការឃុំខ្លួនរយៈពេលបីឆ្នាំជាបណ្តោះអាសន្ន យោងតាមច្បាប់កម្ពុជា ។ ក្នុងពេលនោះ ព្រះរាជអាជ្ញាបានស្នើបន្តឃុំខ្លួន ឌុច ដោយគ្មានការស៊ើបអង្កេត ឬផ្អែកលើមូលដ្ឋាន ច្បាប់ឲ្យបានគ្រប់គ្រាន់ឡើយ ។ ជាមួយគ្នានេះ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចថា ឌុច រួចខ្លួនពីបទចោទប្រកាន់នោះ ឌុច អាចទាមទារសំណងសមស្របចំពោះរយៈពេលដែលត្រូវបានឃុំខ្លួន ដោយប្រព័ន្ធច្បាប់ក្នុងស្រុក ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងរកឃើញពីពិរុទ្ធភាពរបស់ ឌុច នោះ ឌុច អាចមានសិទ្ធិទទួលបាននូវ«ការទូរទាត់»ចំពោះរយៈពេលដែលត្រូវបានឃុំខ្លួនមិនត្រឹមត្រូវតាមច្បាប់ គឺចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ខណៈពេលដែល ឌុច ត្រូវបានបញ្ជូនមកមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយយោងតាម ដីកាចាប់ខ្លួនរបស់សហចៅក្រមស៊ើបអង្កេត ។ ចៅក្រមមិនបានអធិប្បាយពីទម្រង់លក្ខណៈនៃសំណង ដែល ឌុច អាចមានសិទ្ធិទាមទារសម្រាប់ការរំលោភលើសិទ្ធិប្រហាក់ប្រហែលគ្នាផ្សេងទៀតឡើយ ។

ក្នុងសេចក្តីសម្រេចដូចគ្នានេះ ចៅក្រមបានបដិសេធចំពោះសំណើដោះលែង ឌុច ឲ្យនៅក្រៅឃុំ ដោយ កត់សម្គាល់ពី«តម្រូវការចាំបាច់ក្នុងការធានាឲ្យបាននូវវត្តមានចូលរួមក្នុងអង្គសវនាការរបស់ ឌុច» និង

ដោយសារ«កម្រិតនៃឧក្រិដ្ឋកម្មដែល ឌុច ត្រូវបានចោទប្រកាន់» ។ ជាលទ្ធផល ឌុច នឹងត្រូវបន្តឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក រហូតដល់ដំណើរការនីតិវិធីអង្គជំនុំជម្រះធ្វើសេចក្តីសន្និដ្ឋានបញ្ចប់រឿងក្តី ។

ជាមួយគ្នានេះ ចៅក្រមក៏បានប្រកាសពីលទ្ធផលនៃកិច្ចប្រជុំដោយសម្ងាត់ស្តីពីការរៀបចំអង្គសវនការដែលបានផ្អាកដំណើរការនីតិវិធីតាំងពីថ្ងៃសៅរ៍មុននេះ ។ ដោយកត់សម្គាល់ថា ការសន្មត់ថិរវេលាសម្រាប់ការបញ្ចប់អង្គជំនុំជម្រះដែលមានរយៈពេលចាប់ពីខែសីហា ដល់ខែតុលា ឆ្នាំ២០០៩ នោះចៅក្រមបានសម្រេចកំណត់ពេលវេលាសម្រាប់ការសួរសាក្សីផ្សេងទៀត ក្រៅពីជនជាប់ចោទ ឌុច ដោយផ្តល់រយៈពេល៣០នាទីសម្រាប់ព្រះរាជអាជ្ញា ៤០នាទីសម្រាប់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុម និង៤០នាទីសម្រាប់មេធាវីការពារក្តី ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានកាត់បន្ថយរយៈពេលសួរសំណួររបស់ខ្លួនសម្រាប់ការធ្វើកសិណសាក្សីរបស់ដើមបណ្តឹងរដ្ឋប្បវេណីពី៦០ មក៣៧ម៉ោងវិញ ហើយបានសន្មត់ថា ខ្លួននឹងកោះហៅសាក្សីចំនួន២១រូប ដោយមិនរាប់បញ្ចូលទាំងជនរស់រានមានជីវិតឡើយ ។ អង្គជំនុំជម្រះបានកត់សម្គាល់ថា ក្នុងអំឡុងកិច្ចប្រជុំមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងពីក្តីព្រួយបារម្ភទាក់ទិននឹងការខ្វះខាតនូវការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ លក្ខខណ្ឌការងារ និងភាពដែលអាចចូលរួមរបស់មេធាវីមួយចំនួនពីខែសីហា ឆ្នាំ២០០៩តទៅ ។ អង្គជំនុំជម្រះបានពន្យល់ថាក្តីព្រួយបារម្ភទាំងពីរនេះ ដែលស្ថិតនៅក្រៅដែនសមត្ថកិច្ចរបស់អង្គជំនុំជម្រះនឹងត្រូវយកទៅពិចារណាដោយមន្ត្រីរដ្ឋបាលរបស់ អ.វ.ត.ក ហើយបញ្ហាស្តីពីភាពដែលអាចចូលរួមរបស់មេធាវីនឹងត្រូវដោះស្រាយដោយអង្គភាពជនរងគ្រោះរបស់ អ.វ.ត.ក ។ អង្គជំនុំជម្រះក៏បានប្រកាសថា ខ្លួននឹងចំណាយពេលយ៉ាងហោចណាស់មួយថ្ងៃ ដើម្បីដោះស្រាយបន្ទុកការងាររបស់ខ្លួន ហើយបានសន្យាថានឹងផ្តល់នូវកាលវិភាគអង្គសវនការថ្មីក្នុងពេលឆាប់ៗនេះ ។

## ការគេចវេសរបស់ ឌុច ពីការប្រទះឃើញ ស្តាប់ឮ និងហិតក្លិនដែលមាននៅក្នុងមន្ទីរស-២១ ដែលនេះបង្ហាញពី«ភាពហួសជាងមនុស្សកំសាកទៅទៀត»

ថ្ងៃនេះសិស្សវិទ្យាល័យ និងជនជាតិចាមរាប់រយនាក់បានប្រមូលផ្តុំគ្នានៅក្នុងសាលសវនការ ដើម្បីស្តាប់កសិណសាក្សីរបស់ ឌុច ស្តីពីដំណើរប្រតិបត្តិការរបស់គុកទួលស្លែង (មន្ទីរស-២១) ។ ខ្ញុំគិតថា ក្នុងដំណើរទស្សនកិច្ចមកកាន់ទីក្រុងភ្នំពេញ ប្រជាជនដែលមកតាមដានអង្គសវនការក្នុងថ្ងៃនេះ ប្រហែលជា

មិនអាចបរិភោគអាហារថ្ងៃត្រង់របស់ខ្លួនដោយស្រួលចិត្តនោះទេ ក្រោយពីការបង្ហាញ និងពន្យល់លម្អិតលើរូបថតអ្នកទោសមន្ទីរស-២១ដែលរងប្រព្រឹត្តិកម្មផ្សេងៗ ។ អ្នកដែលរួមតុអាហារជាមួយខ្ញុំក៏មិនមានអារម្មណ៍ចង់បរិភោគអាហារថ្ងៃត្រង់ដែរ ។ នេះគឺជាថ្ងៃដ៏អាប់អួរមួយក្នុងអង្គសវនការ ។

ចោទសួរដោយចៅក្រម ឌុច បានពន្យល់ថា អ្នកទោសប្រុសត្រូវបានចងភ្នែក ដាក់ខ្នោះ និងដោះសម្លៀកបំពាក់ចេញទុកតែខោក្នុង ក្រោយពីអ្នកទោសទាំងនោះមកដល់មន្ទីរស-២១ ហើយបន្ទាប់មកពួកគេត្រូវបានថតរូប និងនាំទៅឃុំខ្លួនក្នុងគុកទាំងជាប់ខ្នោះក្នុងរយៈពេល២៤ម៉ោងក្នុងមួយថ្ងៃ ។ អ្នកទោស“មិនសំខាន់”ត្រូវនាំទៅឃុំខ្លួននៅក្នុងបន្ទប់អ្នកទោសរួម ហើយដាក់ខ្នោះជាជួរជាមួយអ្នកទោសផ្សេងទៀត ។ អ្នកទោសទាំងនោះមិនអាចឲ្យអង្គុយ ឬនិយាយឆ្លងឆ្លើយគ្នា ដោយគ្មានការអនុញ្ញាតទេ ។ ដោយសារតែគ្មានបន្ទប់ទឹក អ្នកទោសទាំងអស់ត្រូវបង្ខំឲ្យបន្ទោរបង់នៅក្នុងកន្លែងឃុំខ្លួនតែម្តង ។ អ្នកទោសមិនអនុញ្ញាតឲ្យប្តូរសម្លៀកបំពាក់ទេ ហើយ“ការងូតទឹកសម្អាត”ត្រូវបានធ្វើឡើងដោយបាញ់ទឹកនឹងបំពង់ទុយោ ។ ទង្វើរនេះគឺធ្វើក្នុងគោលបំណងសម្អាតឥដ្ឋការូ ជាជាងសម្អាតអ្នកទោសទៅវិញ ។ គ្មានការផ្គត់ផ្គង់សម្រាប់ការសម្រាក ដូចជាផ្តល់ខ្នើយ ភួយ ឬមុងឡើយ ។ ឌុច បាននិយាយថា គ្រែដែលឃើញនៅក្នុងរូបថតខ្លះរបស់មន្ទីរស-២១នោះ បានបន្ថែមសម្រាប់អ្នកទោសក្រោយពីឆ្នាំ១៩៧៩ ។ អ្នកទោសមិនអនុញ្ញាតឲ្យចេញទៅក្រៅគុកទេ លុះត្រាតែពួកគេត្រូវបានចាត់តាំងឲ្យទៅធ្វើការងារពលិកម្មតែប៉ុណ្ណោះ ។ អ្នកទោសមិនដែលត្រូវបានដោះខ្នោះ ឬដោះលែងឡើយ បើទោះបីជាអ្នកទោសមានជម្ងឺក៏ដោយ ។ បន្ថែមលើនេះ អ្នកទោសនឹងទទួលបានថ្នាំព្យាបាលនៅពេលដែលបុគ្គលិកមន្ទីរស-២១ ចង់ទុកឲ្យអ្នកទោសនោះនៅរស់ ឬបន្តសួរចម្លើយតែប៉ុណ្ណោះ ។ ក្រោយមកទៀត បុគ្គលិកព្យាបាលអ្នកជម្ងឺត្រូវបានចាត់ទុកថា ជាខ្មាំង ហើយត្រូវបានឃុំខ្លួននៅមន្ទីរស-២១ ។ ដូច្នេះ ឌុច ត្រូវតែមករកអ្នកទោសទាំងនោះវិញ ដើម្បីសួរនាំពីការព្យាបាលជម្ងឺ ។

ឌុច បានពន្យល់ថា មន្ទីរស-២១ គឺជាកន្លែងឃុំខ្លួនមនុស្សមុនពេលយកទៅសម្លាប់ ដូច្នេះគ្មានច្បាប់ស្តីពីការការពារសិទ្ធិបុគ្គលនោះទេ ។ អ្នកទោសទាំងអស់ត្រូវបានទទួលរងអំពើដូច“មនុស្សគ្មានជីវិត” និង“ចាត់ទុកដូចជាសត្វធាតុ” ។ ឌុច បាននិយាយថា គាត់ដឹងថាអ្នកទោសជាច្រើននាក់ស្លាប់ដោយសារការអត់ឃ្លានព្រោះរបបអាហារតិចតួច ។ ឌុច បានរៀបរាប់ថា គ្មាននរណាម្នាក់ក្នុងប្រទេសកម្ពុជាទទួលបានអាហារបរិភោគគ្រប់គ្រាន់ទេ ហេតុដូច្នេះហើយបានជា ឌុច មានទម្ងន់តែ៤៩គីឡូប៉ុណ្ណោះ ក្នុងអំឡុងពេលនោះ ។

អ្នកទោស«ពិសេស» ឬអ្នកទោស«សំខាន់»ទទួលបានលក្ខខណ្ឌរបបអាហារប្រសើរជាងតែបន្តិចប៉ុណ្ណោះ ដូចជាមានគុកឃុំខ្លួនដាច់ដោយឡែក និងទទួលរងនូវប្រព្រឹត្តិកម្ម«សមរម្យ»ដោយសារតែថ្នាក់លើរបស់ ឌុច ចាប់អារម្មណ៍លើចម្លើយសារភាពរបស់អ្នកទោសទាំងនោះដែលអាចជាប់ពាក់ព័ន្ធនឹងមនុស្សដទៃទៀតនៅក្នុងថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ។ ខណៈពេលដែលមិនមានការយល់ស្របគ្នាលើចំនួនអ្នកទោសជនជាតិបរទេស ឌុច បានបញ្ជាក់ថា អ្នកទោសជនជាតិបរទេសមួយចំនួនតូចក៏ទទួលរងនូវប្រ-ព្រឹត្តិកម្មប្រសើរដែរ ។

ស្ត្រី និងកុមារមានចំនួន២៣ភាគរយក្នុងចំណោមជនរងគ្រោះទាំងអស់នៅមន្ទីរស-២១ ហើយពួកគេទាំងអស់ក៏ត្រូវបានទទួលរងនូវប្រព្រឹត្តិកម្មខុសប្លែកគ្នាដែរ ។ ជាទូទៅស្ត្រីអនុញ្ញាតឲ្យស្លៀកសម្លៀកបំពាក់ និងចេញក្រៅមន្ទីរឃុំឃាំងរបស់ខ្លួនពេលខ្លះ ។ នៅមន្ទីរស-២១ក៏មានអ្នកសួរចម្លើយស្រីដែរ ប៉ុន្តែមិនមានអ្នកយាមគុកស្រីទេ ។ យ៉ាងហោចណាស់ពាក់កណ្តាលនៃអ្នកទោសស្រីទាំងអស់ត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ ដោយសារតែទំនាក់ទំនងរបស់គេជាមួយនឹងអ្នកទោសប្រុស ។ ជាមួយគ្នានេះ អ្នកទោសស្រីភាគច្រើនត្រូវបានជឿថា មិនបានប្រព្រឹត្តបទល្មើសអ្វីទេ ។ ស្ត្រីទាំងនោះត្រូវបានបំបែកចេញពីកូនរបស់គេ ដែលមានពេលខ្លះកូននោះអាចមានអាយុត្រឹមតែមួយខួបក៏មានដែរ ។ ការធ្វើដូច្នេះគឺដើម្បីឲ្យសួរចម្លើយអ្នកទោសស្រីទាំងនោះ ហើយចំណែកឯកូនក្មេងវិញត្រូវ«កម្ទេច»ចោល ។ នៅក្នុងមន្ទីរស-២១ មានគោលនយោបាយដ៏តឹងរឹងមួយដែលមិនអនុញ្ញាតឲ្យមានការទាក់ទងរវាងសមាជិកគ្រួសារឡើយ ។

ក្រៅពីការរៀបរាប់ពីទិដ្ឋភាពដ៏រន្ធត់ស្តីពីស្ថានភាពមន្ទីរស-២១មក ចំនុចដែលគួរឲ្យចាប់អារម្មណ៍បំផុតសម្រាប់ការធ្វើកសិណសាក្សីក្នុងថ្ងៃនេះ គឺការធ្វើខ្លួនឲ្យឃ្លាតឆ្ងាយចេញពីដំណើរប្រតិបត្តិការប្រចាំថ្ងៃរបស់មន្ទីរស-២១ បើទោះបីជា ឌុច ជាប្រធាន និងមានការិយាល័យនៅក្បែរមន្ទីរស-២១ក៏ដោយក៏ ឌុច បានអះអាងថា គាត់មិនដែលទៅពិនិត្យមើលមន្ទីរឃុំខ្លួនរួមនោះទេ ប៉ុន្តែ បានពិនិត្យមើលមន្ទីរឃុំខ្លួនអ្នកទោសពិសេសម្តងម្កាលតែប៉ុណ្ណោះ ។ ឌុច មិនអាចឆ្លើយនឹងសំណួរសាមញ្ញជាច្រើនដូចជា តើអ្នកទោសស្រីមានបន្ទប់ទឹកប្រើប្រាស់ដែរឬទេ ឬក៏ថាតើសម្លៀកបំពាក់របស់អ្នកទោសទាំងអស់នោះយកមកធ្វើអ្វី ។ ឌុច មិនអាចនិយាយថា មានសម្លេងស្រែក ឬក៏ក្លិនស្អុយបានទេ ។ ជួនពេលខ្លះ ឌុច បានណែនាំឲ្យចៅក្រមសួរសំណួរលម្អិតស្តីពីដំណើរប្រតិបត្តិការរបស់មន្ទីរស-២១ ទៅកាន់សាក្សីបន្ទាប់ទៀតដូចជា សមមិត្ត ហ៊ី ដែលជាអនុប្រធានរបស់ ឌុច ។

ក្រោយពេលដែលឃើញ ឌុច ធ្វើការការពារខ្លួនយ៉ាងសកម្មបែបនេះ វាពិតជាលំបាកក្នុងការគិតថា ឌុច មិនយកចិត្តទុកដាក់នឹងការគ្រប់គ្រងមន្ទីរស-២១នេះ ។ នៅអង្គជំនុំជម្រះវិញ ឌុច គឺជាមនុស្សដែលរៀបចំខ្លួនបានល្អ និងល្អិត ។ ឌុច បានលើកឡើងពីចំនួនឯកសារយោងដែលមានជា៨ឯកសារផ្សេងៗគ្នាដោយផ្អែកលើការចងចាំ ។ ឌុច បានកែតម្រូវអ្នកបកប្រែលំដាប់ពិភពលោកក្នុងការបកប្រែជាភាសាបារាំង ។ ឌុច ព្យាយាមទាមទារនូវព័ត៌មានទាំងអស់ដែលមាននៅក្នុងកំណត់ហេតុទាំងធំតូច ។ ជាសំណាងល្អ នាពេលចុងបញ្ចប់នៃអង្គសវនការសម្រាប់ថ្ងៃនេះ ចៅក្រម ឡាវែន បានជម្រុញឲ្យ ឌុច បញ្ឈប់ពីការអះអាងដែលថា ឌុច មិនបានទៅត្រួតពិនិត្យមន្ទីរស-២១ ។ ចុងក្រោយបង្អស់ ឌុច បានប្រាប់ពីអារម្មណ៍របស់គាត់ និងធ្វើឲ្យចៅក្រមយល់ពីស្ថានភាពរបស់គាត់ ។ ឌុច បានពន្យល់ថា មិនមែនមកពីឃ្លានស្អុយនោះទេដែលធ្វើឲ្យ ឌុច មិនមកមន្ទីរស-២១ ។ ផ្ទុយទៅវិញ ឌុច មិនអាចទ្រាំមើលភាពឈឺចាប់របស់អ្នកដែលនៅក្រោមបង្គាប់របស់គាត់ ហើយមិនអាចឲ្យមិត្តដែលគាត់បានបោកប្រាស់នោះឃើញមុខគាត់ឡើយ ។ ឌុច បាននិយាយថា គាត់ត្រូវតែគេចចេញពីមន្ទីរស-២១ ពីព្រោះថារាល់ពេលដែល ឌុច ដើរទៅក្បែរមន្ទីរស-២១នោះ គាត់នឹងមានអារម្មណ៍ស្រណោះស្រណោក ។ ឌុច បាននិយាយថា “ខ្ញុំបានបិទភ្នែក បិទត្រចៀករបស់ខ្ញុំ ។ ខ្ញុំមិនចង់ឃើញស្ថានភាពជាក់ស្តែងទាំងអស់នោះទេ” ។ ចៅក្រម ឡាវែន បានសួរថា តើទង្វើរបែបនេះគួរតែចាត់ទុកថា ជា“ភាពកំសាក”ដែរឬទេ? ឌុច ក៏បានឆ្លើយតបថា “ខ្ញុំគិតថា វាហួសពីភាពកំសាកទៅទៀត” ។